**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣០ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការបង្កើត នាយកដ្ឋានការពារគីមីសាស្ត្រ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## <u>ស ម្រេ ច</u>

<u>**មាត្រា១**</u> **:** ត្រូវបានបង្កើត នាយកដ្ឋានការពារគីមីសាស្ត្រ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ ។

<u>**មាត្រា២**</u> **:**

**ក/-តួនាទី :**

នាយកដ្ឋានការពារគីមីសាស្ត្រ និងជីវៈជាតិពុលជាស្ថាប័នមួយស្ថិតនៅក្រោមការដឹកនាំ និងបញ្ជាផ្ទាល់របស់ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ មានតួនាទីធ្វើជាសេនាធិការឱ្យអគ្គនាយកដ្ឋានសំភារៈបច្ចេកទេស ក្នុងការស្រាវជ្រាវ រុករក បំផ្លាញ ការពារ អាវុធគីមីសាស្ត្រ ជីវសាស្ត្រ និងអាវុធប្រល័យលោកដទៃទៀត ។

**ខ/-ភារកិច្ច :**

នាយកដ្ឋានការពារគីមីសាស្ត្រ មានភារកិច្ចដូចខាងក្រោម ÷

-ផ្សព្វផ្សាយអំពីប្រសិទ្ធិភាព និងវិធីការពារជាតិពុលប្រភេទអាវុធគីមីសាស្ត្រ ជីវសាស្ត្រ វិទ្យុសកម្ម និងប្រភេទអាវុធប្រល័យលោក ឱ្យដល់កងយោធពលខេមរភូមិន្ទ និងប្រជាពលរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ។

-កសាងកម្លាំងការពារគីមីសាស្ត្រ និងជំរះជាតិពុលក្នុងកងកម្លាំងប្រដាប់អាវុធឱ្យស្របតាមការវិវត្តន៍របស់សង្គ្រាមគីមីសាស្ត្រ និងបច្ចេកវិទ្យាទំនើប ។

-សហការណ៍ស្រាវជ្រាវ រុករក ពិសោធន៍ ឱ្យឃើញគ្រប់ករណីជាតិពុល ជីវសាស្ត្រ វិទ្យុសកម្ម ក្នុងភូមិសាស្ត្រកងទ័ព និងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

-ហ្វឹកហ្វឺនឱ្យដល់យោធិនយល់ដឹង និងចេះប្រើប្រាស់សម្ភារៈការពារអំពីអាវុធគីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

-សហការណ៍ជួយសង្គ្រោះ បន្សាបជាតិពុល ជីវសាស្ត្រ វិទ្យុសកម្ម ទាំងក្នុងកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋក្នុងលក្ខខ័ណ្ឌបន្ទាន់ ។

-សហការណ៍ជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាពីគ្នាទៅវិញទៅមក ។

-ណែនាំ ហ្វឹកហ្វឺន និងបំប៉នជំនាញ ឱ្យខ្សែរយៈជំនាញថ្នាក់ក្រោម ។

-ក្រៅពីនេះ នាយកដ្ឋានការពារគីមីសាស្ត្រ អាចទទួលការងារជាក់ស្តែងដ៏ទៃទៀតតាមការប្រគល់ភារកិច្ចរបស់អគ្គនាយកដ្ឋាន សំភារៈបច្ចេកទេស ។

**មាត្រា៣** : នាយកដ្ឋានការពារគីមីសាស្ត្រ ដឹកនាំដោយ នាយក មួយរូប និងនាយករង មួយរូប ឬច្រើនរូបតាមតម្រូវការ ។ ការរៀបចំរចនាសម្ព័ន្ធរបស់ នាយកដ្ឋានការពារគីមីសាស្ត្រ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា៤** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៥** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ